អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១២

# សេចក្តីបំភ្លឺរបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ
# ទៅនឹងកំណត់សំគាល់របស់លោក Laurent KASPER-ANSERMET
# លេខ D38 ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០១២

ឆ្លើយតបនឹងកំណត់សំគាល់ របស់លោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ទាក់ទងនឹងការបញ្ជូនត្រឡប់វិញនូវសំណុំឯកសារដែលការិយាល័យរដ្ឋបាលផ្ញើជូនអង្គបុរេជំនុំជម្រះ តាមរយៈលិខិតលេខ១០៩៤ អវតក/Ad ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ និងតាមរយៈលិខិតលេខ១០១៤ អវតក/រប ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ និងទាក់ទងនឹងសំណើសុំដាក់បណ្តឹងដិតចិត្តចំពោះចៅក្រម ប្រាក់ គឹមសាន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២ របស់លោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះសូមបង្ហាញហេតុផលពិតដូចតទៅ៖

លោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានចូលបំពេញការងារនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយចាប់ផ្តើមពីទំនាក់ទំនងជាមួយសហចៅក្រមស៊ើបអង្កេតជាតិ តាមរយៈលិខិតចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១១ ហើយលោក Laurent បានទទួលនូវការឆ្លើយតបពីសហចៅក្រមស៊ើបអង្កេតជាតិវិញ តាមរយៈលិខិតចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ និងសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។

ក្នុងលិខិតចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតជាតិ បានបញ្ជាក់ជាអាទិថា៖ "…..អំពីការចាប់ផ្តើមចំណាត់ការនីតិវិធីដែលខ្ញុំអាចពិភាក្សាជាមួយលោកចៅក្រមបាន គឺក្រោយពេលមានការតែងតាំងលោកចៅក្រមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាជាមុនសិន…."។

តាមសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតជាតិបានបញ្ជាក់ជាថ្មីទៀតថា៖ "….សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ត្រូវតែរង់ចាំទទួលការតែងតាំងជាផ្លូវការតាមនីតិវិធីជាធរមានជាមុនសិន មុននឹងចាប់ផ្តើមការងាររបស់ខ្លួន"។

តាមខ្លឹមសារឯកសារទាំងពីរខាងលើ លោក Laurent ពុំបានជួបប្រជុំពិភាក្សាដើម្បីចាប់ផ្តើមធ្វើការងារជាមួយសហចៅក្រមស៊ើបអង្កេតជាតិដែលឈានទៅដល់ការខ្វែងយោបល់ បង្កើតបានជាកំណត់ហេតុនៃការខ្វែង

យោបល់គ្នាទាក់ទងនឹងកិច្ចស៊ើបសួរណាមួយ ដែលលោក Laurent ចង់ធ្វើ ឬចាប់ផ្តើមធ្វើក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ឡើយ។ ដូច្នេះអ្វីដែលកើតឡើងនៅការិយាល័យសហចៅក្រមស៊ើបអង្កេត គឺវិវាទទាក់ទងនឹងនីតិសម្បទារបស់លោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងដែលពុំស្ថិតនៅក្នុងសមត្ថកិច្ចនៃ អវតក ឡើយ។ ដោយសារនៅការិយាល័យសហចៅក្រមស៊ើបអង្កេត កំពុងតែមានការយល់មិនស្របគ្នាលើបញ្ហានីតិសម្បទា នោះលោក Laurent មិនគួរព្យាយាមធ្វើកិច្ចណាមួយ ឬដាក់សំណើណាមួយមកអង្គបុរេ ជំនុំជម្រះឲ្យដោះស្រាយនោះទេ លោកគួរតែស្វែងរកការបញ្ជាក់ពីនីតិសម្បទារបស់លោកតាមផ្លូវច្បាប់ពីស្ថាប័នមានសមត្ថកិច្ចជាមុន មុននឹងបន្តកិច្ចនីតិវិធីណាមួយក្នុងការស៊ើបសួររបស់លោកព្រោះថា អង្គបុរេជំនុំជម្រះមិនមានយុត្តាធិការក្នុងការដោះ-ស្រាយបញ្ហានីតិសម្បទានោះទេ ប៉ុន្តែលោកនៅតែបង្ខំធ្វើកិច្ចការទាំងនេះដោយបំពានទាំងខ្លួនពុំទាន់ទទួលបាននីតិសម្បទាស្របច្បាប់ពីស្ថាប័ន្ថមានសមត្ថកិច្ច ដែលជាហេតុបង្កើតអោយមានរឿងរ៉ាវទាំងអស់ ដែលទាក់ទងនឹងសំណុំរឿង០០៣ និង ០០៤ ដោយឥតអៀនខ្មាស ហើយប្រែក្លាយរឿងរ៉ាវទាំងនេះ អោយទៅជារឿងថ្មីមួយទៀតក្រោមរូបភាពជា“កំណត់ហេតុនៃការខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត” ហើយបញ្ជូនកំណត់ហេតុដែលលោក Laurent ចាត់ទុកថាជាការខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេតមកចំពោះមុខអង្គបុរេជំនុំជម្រះដើម្បីដោះស្រាយជាសមត្ថកិច្ចតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង។

ទង្វើរបស់លោក Laurent បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថែមទៀត តាមរយៈកំណត់សំគាល់របស់លោកចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០១២ ក្នុងកថាខណ្ឌ ១៧ ដល់ ២០។ លោក Laurent បានបង្ហាញជូនសាធារណៈជនដោយឥតអៀនខ្មាសនូវរាល់ហេតុការណ៍ដែលកើតមានឡើង ដែលពុំមែនជា “ការខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេតទាល់តែសោះ”។

ដូច្នេះលោក Laurent ជាអ្នកប្រឌិត “កំណត់ហេតុនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត” លោក Laurent ជាអ្នកបង្កើតនូវនីតិវិធីច្របូកច្របល់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដែលពុំធ្លាប់កើតមានពីមុនមក បង្កើតបានជាអនីយ័តភាពក្នុងការដោះស្រាយរឿងនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ អាស្រ័យហេតុនេះ មធ្យោបាយតែមួយគត់ដើម្បីកំចាត់ភាពច្របូកច្របល់ទាំងនេះ សំណុំឯកសារទាំងមូលត្រូវបញ្ជូនត្រឡប់ទៅម្ចាស់ដើមវិញតាមរយៈលិខិតចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២។

បន្ទាប់មក នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ មានសំណុំឯកសារមួយត្រូវបានបញ្ជូនមកចំពោះមុខអង្គបុរេជំនុំជម្រះ។ នៅពេលនោះក្រឡាបញ្ជីបានដាក់សំណុំឯកសារនេះ ជូនប្រធានអង្គបុរេជំនុំជម្រះដើម្បីពិនិត្យ។ បន្ទាប់ពីបានពិនិត្យសំណុំឯកសារនេះឃើញថា ជាសំណុំឯកសារដែលចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១១ និងចុះថ្ងៃទី១៩ ខែ មករា ឆ្នាំ២០១២ របស់លោក Laurent ដដែល ដោយមិនមានអ្វីប្រែប្រួលនោះទេ ហើយក៏មិនបានដាក់ភ្ជាប់នូវលិខិតបញ្ជាក់ពីនីតិសម្បទាតាមផ្លូវច្បាប់របស់ខ្លួន ដើម្បីបំពេញនូវចំណុចខ្វះខាត។ សំណុំឯកសារនេះមិនបានទទួលយកមកដោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះទេ ដោយលោកប្រធានអង្គបុរេជំនុំជម្រះមិនអនុញ្ញាតអោយក្រឡាបញ្ជីទទួលយកសំណុំឯកសារនេះ។

ដោយលោកមិនសុខចិត្តនឹងការសម្រេចខាងលើ នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២ ដោយលោក Laurent បានដាក់ពាក្យបណ្តឹងប្តឹងជំទាស់ប្រធានអង្គបុរេជំនុំជម្រះ។

ឆ្លើយតបនឹងសំណើសុំដាក់បណ្តឹងជំទាស់នេះ តាមរយៈលិខិតចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ លោកចៅ-ក្រម ប្រាក់ គឹមសាន សម្រេចពុំទទួលយកមកពិចារណាឡើយ ដោយហេតុថាលោក Laurent ពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការប្តឹងជំទាស់ចំពោះរូបលោក។